Australian Government
Services Australia

KHMER

# ការធ្វើសមតុល្យលើការបង់ប្រាក់ជំនួយគ្រួសាររបស់អ្នក

ក្រោយចុងឆ្នាំហិរញ្ញវត្ថុ
យើងប្រៀបធៀបការប៉ាន់ស្មានប្រាក់ចំណូលគ្រួសាររបស់អ្នកជាមួយនឹងចំណូលជាក់ស្តែងរបស់អ្នក។ ការធ្វើដូចនេះគឺដើម្បីធ្វើឱ្យប្រាកដថាយើងបានបង់ប្រាក់ឱ្យអ្នកនូវចំនួនប្រាក់ជំនួយគ្រួសារបានត្រឹមត្រូវ។ ដំណើការនេះហៅថាការធ្វើសមតុល្យ។

## អ្វីខ្លះដែលអ្នកត្រូវធ្វើ

មិនមែនមនុស្សគ្រប់រូបត្រូវតែធ្វើការងារដូចគ្នាសម្រាប់យើងនៅក្នុងការធ្វើសមតុល្យលើ Family Tax Benefit និង Child Care Subsidy របស់ពួកគេនោះទេ។ អ្វីដែលអ្នកត្រូវធ្វើអាស្រ័យលើកាលៈទេសៈរបស់អ្នក។

អ្នកអាចត្រូវការដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធ ប្រសិនបើអ្នកមានដៃគូ ពួកគេអាចត្រូវការធ្វើកិច្ចការនេះផងដែរ។ ដើម្បីពិនិត្យមើថាតើអ្នកត្រូវការដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធឬអត់ សូមទៅកាន់គេហទំព័ររបស់ Australian Taxation Office (ATO)។

ប្រសិនបើអ្នក ឬដៃគូរបស់អ្នកដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធ នោះ ATO នឹងផ្ញើឱ្យអ្នកនូវព័ត៌មានអំពីប្រាក់ចំណូលរបស់អ្នក។ ជាធម្មតា យើងទទួលបានព័ត៌មាននេះនៅក្នុងរយៈពេល 28 ថ្ងៃ ចាប់ពីពេលអ្នកទទួលបាន Notice of Assessment សេចក្តីជូនដំណឹងអំពីការវាយតម្លៃរបស់អ្នកពីពួកគេ។

ប្រសិនបើអ្នក ឬដៃគូអ្នកមិនត្រូវការដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធទេ។ អ្នកត្រូវការប្រាប់ឱ្យយើងដឹងនិងបញ្ជាក់អំពីប្រាក់ចំណូលគ្រួសាររបស់អ្នក។ អ្នកអាចផ្តល់ព័ត៌មាននេះដល់យើងដោយប្រើគណនីអនឡាញ Centrelink របស់អ្នក តាមរយៈកម្មវិធីឧបករណ៍ចល័ត myGov ឬ Express Plus Centrelink។

ប្រសិនបើអ្នកបានបែកពីដៃគូក្នុងអំឡុងពេលឆ្នាំហិរញ្ញវត្ថុ យើនឹងធ្វើសមតុល្យ Family Tax Benefit របស់អ្នក ក្រោយអ្នកបញ្ជាក់ប្រាក់ចំណូលរបស់អ្នក។ យើងនឹងប្រើការប៉ាន់ស្មានប្រាក់ចំណូលដែលបានផ្តល់សម្រាប់អតីតដៃគូរបស់អ្នក ប្រសិនបើពួកគេមិនបានដាក់ប្រតិវេទន៍ពន្ធ។ ប្រសិនបើអ្នកបានទទួល Child Care Subsidy នោះអ្នកនឹងត្រូវការទាក់ទងយើងដើម្បីបញ្ជាក់ប្រាក់ចំណូលរបស់អតីតដៃគូរបស់អ្នក។ អ្នកមិនត្រូវការទាក់ទងអតីតដៃគូរបស់អ្នកសម្រាប់ព័ត៌មាននេះទេ។

ឪពុកម្តាយភាគច្រើនដែលបង់ប្រាក់ ឬទទួល child support ត្រូវតែដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធ។ នៅពេល ATO វាយតម្លៃលើប្រតិវេទន៍ពន្ធរបស់អ្នក ពួកគេនឹងផ្ញើឱ្យយើងនូវព័ត៌មានលម្អិតអំពីប្រាក់ចំណូលរបស់អ្នក។ យើងនឹងប្រើប្រាស់ព័ត៌មាននេះដើម្បីធ្វើបច្ចុប្បន្នភាពលើការវាយតម្លៃ child support របស់អ្នក។ ប្រសិនបើ ATO មិនទាន់បានវាយតម្លៃលើប្រាក់ចំណូលអាចកាត់ពន្ធរបស់អ្នកនៅឡើយទេ ឬប្រសិនបើអ្នកមិនត្រូវការដាក់ពាក្យធ្វើប្រតិវេទន៍ពន្ធទេ អ្នកនៅតែត្រូវការប្រាប់យើងអំពីប្រាក់ចំណូលរបស់អ្នក។ អ្នកអាចធ្វើកិច្ចការនេះដោយប្រើគណនីអនឡាញ Child Support របស់អ្នកតាមរយៈ myGov។

## ពេលវេលាដែលយើងធ្វើសមតុល្យលើការបង់ប្រាក់របស់អ្នក

យើងអាចធ្វើសមតុល្យលើ Family Tax Benefit របស់អ្នកតែក្រោយពីយើងបានបង់ប្រាក់ Family Tax Benefit ចុងក្រោយរបស់អ្នកសម្រាប់ឆ្នាំហិរញ្ញវត្ថុ ហើយអ្នកបានបញ្ជាក់ប្រាក់ចំណូលរបស់អ្នករួចហើយ ប៉ុណ្ណោះ។ ជាធម្មតា អ្នកនឹងទទួលបានការបង់ប្រាក់ចុងក្រោយរបស់អ្នកនៅត្រឹមពាក់កណ្តាលខែកក្កដា។

នៅពេលយើងធ្វើសមតុល្យលើ Family Tax Benefit របស់អ្នក យើងពិនិត្យមើលថាតើអ្នកគួរត្រូវបានបង់ឱ្យចំនួនបន្ថែមណាមួយឬអត់។ នេះរួមមានប្រាក់បន្ថែម Family Tax Benefit Part A supplement, ប្រាក់បន្ថែម Family Tax Benefit Part B supplement និង Single Income Family Supplement។

យើងចាប់ផ្តើមធ្វើសមតុល្យលើ Child Care Subsidy ក្រោយ Family Tax Benefit។ នៅពេលយើងអាចធ្វើសមតុល្យលើ Child Care Subsidy របស់អ្នកបាន យើងបញ្ជាក់អំពីការចូលរៀននៅសាលារបស់កូនអ្នកសម្រាប់ឆ្នាំហិរញ្ញវត្ថុនោះ។ យើងទទួលបានព័ត៌មាននេះដោយផ្ទាល់ពីសេវាកម្មថែទាំកូនរបស់អ្នក។

យើងរក្សាទុកភាគរយនៃ Child Care Subsidy របស់អ្នក ដើម្បីកាត់ទូទាត់ជាមួយការបង់ប្រាក់លើសណាមួយដែលអាចកើតមាន។ ប្រសិនបើអ្នកមិនមានការបង់ប្រាក់លើសទេ យើងនឹងបង់ដោយផ្ទាល់ចំនួនណាមួយដែលយើងបានរក្សាទុកទៅឱ្យអ្នកនៅពេលយើងធ្វើសមតុល្យលើ Child Care Subsidy របស់អ្នក។

នៅពេលយើងបានធ្វើសមតុល្យលើការបង់ប្រាក់របស់អ្នករួចហើយ យើងនឹងផ្ញើឱ្យអ្នកនូវលិខិតមួយដែលពន្យល់អំពីលទ្ធផល។ ប្រសិនបើអ្នកទទួលបានលិខិតជាអេឡិចត្រូនិករបស់អ្នក នោះយើងនឹងផ្ញើវាទៅប្រអប់សារចូល myGov របស់អ្នក។ អ្នកអាចពិនិត្យមើលថាតើ Family Tax Benefit និង Child Care Subsidy របស់អ្នកត្រូវបានធ្វើសមតុល្យដោយប្រើកម្មវិធីឧបករណ៍ចល័ត Express Plus Centrelink របស់អ្នកឬអត់។ អ្នកក៏អាចពិនិត្យមើលផងដែរថាតើ Child Care Subsidy របស់អ្នកត្រូវបានធ្វើសមតុល្យ ដោយប្រើគណនីអនឡាញ Centrelink របស់អ្នកតាមរយៈ myGov ឬអត់។

# របៀបយល់អំពីលទ្ធផលធ្វើសមតុល្យរបស់អ្នក

មានលទ្ធផលធ្វើសមតុល្យចំនួន 3 ដែលអាចមាន៖

- អ្នកមិនត្រូវបានបង់ឱ្យបានគ្រប់គ្រាន់
- អ្នកត្រូវបានបង់ឱ្យច្រើនពេក
- គ្មានការផ្លាស់ប្តូរ។

## អ្នកមិនត្រូវបានបង់ឱ្យបានគ្រប់គ្រាន់

ប្រសិនបើយើងមិនបានបង់ឱ្យអ្នកបានគ្រប់គ្រាន់នៅក្នុងឆ្នាំនោះទេ យើងនឹងបង់ចំនួនដែលនៅជំពាក់ណាមួយដោយផ្ទាល់ទៅឱ្យអ្នក នៅពេលយើងធ្វើសមតុល្យលើការបង់ប្រាក់របស់អ្នក។ យើងហៅចំនួននេះថាប្រាក់បំពេញ។

ប្រសិនបើអ្នកមានបំណុល Centrelink នោះយើងអាចយកវាមកវិញពីប្រាក់បំពេញ Family Tax Benefit និងប្រាក់បន្ថែមរបស់អ្នក។

ប្រសិនបើអ្នកមានបំណុលថែទាំកូន យើងអាចយកវាមកវិញពី Child Care Subsidy និងប្រាក់បំពេញ Additional Child Care Subsidy របស់អ្នក។

ការនេះអាចកើតឡើងទោះបីជាអ្នកបានចូលរួមជាមួយយើងនៅក្នុងការចាត់ចែងការបង់ប្រាក់សងវិញក៏ដោយ។

ការបង់ប្រាក់លើប្រាក់បំពេញ Family Tax Benefit និងប្រាក់បន្ថែម ក៏អាចត្រូវបានប្រើប្រាស់ដោយ ATO ដើម្បីទារយកមកវិញនូវបំណុលពន្ធផងដែរ។

## អ្នកត្រូវបានបង់ឱ្យច្រើនពេក

ប្រសិនបើអ្នកបានទទួល Child Care Subsidy ឬ Family Tax Benefit ច្រើនពេកនៅក្នុងអំឡុងនៃឆ្នាំ អ្នកអាចជំពាក់ប្រាក់យើង ហើយអ្នកនឹងត្រូវបង់សងមកវិញ។

ដើម្បីបង់ប្រាក់សងមកវិញ អ្នកត្រូវការបញ្ចូលទៅក្នុងគម្រោងបង់ប្រាក់សងវិញជាមួយយើង។ អ្នកត្រូវតែធ្វើកិច្ចការនេះទៅតាមកាលបរិច្ឆេទដែលជំពាក់នៅក្នុងលិខិតរបស់អ្នក។

យើងអាចយកមកវិញនូវការបង់ប្រាក់លើសនៃ Child Care Subsidy និង Family Tax Benefit ពីការបង់ប្រាក់ទាំងអស់ដូចខាងក្រោម៖

- ការបង់ប្រាក់សម្រាប់ Family Tax Benefit នាពេលអនាគតរបស់អ្នក
- ប្រាក់បំពេញ Family Tax Benefit និងប្រាក់បន្ថែមរបស់អ្នក
- ប្រាក់ពន្ធបង់សងវិញ។

យើងអាចយកមកវិញនូវការបង់ប្រាក់លើសម្រាប់ការថែទាំកូនពី Child Care Subsidy ឬប្រាក់បំពេញ Additional Child Care Subsidy របស់អ្នក

ការនេះអាចកើតឡើងទោះបីជាអ្នកបានចូលរួមជាមួយយើងនៅក្នុងការចាត់ចែងការបង់ប្រាក់សងវិញក៏ដោយ។

អ្នកអាចពិនិត្យមើលបំណុល Centrelink អនឡាញរបស់អ្នក។ ជ្រើសរើស ‘**Money You Owe**’ ពីគណនីអនឡាញ Centrelink របស់អ្នក តាមរយៈ myGov ឬតាមរយៈការប្រើប្រាស់កម្មវិធីឧបករណ៍ចល័ត Express Plus Centrelink។

ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងសេចក្តីសម្រេចដែលយើងបានធ្វើ អ្នកអាចស្នើសុំឱ្យយើងវាយតម្លៃវាឡើងវិញបាន។

ជាការសំខាន់អ្នកត្រូវនិយាយជាមួយយើង ប្រសិនបើអ្នកព្រួយបារម្ភអំពីការបង់សងបំណុលវិញ។ យើងអាចធ្វើការជាមួយអ្នកដើម្បីរៀបចំគម្រោងបង់សងវិញដែលអ្នកអាចលៃលកបាន។

### គ្មានការផ្លាស់ប្តូរ

ប្រសិនបើយើងបានបង់ឱ្យអ្នកនូវចំនួនត្រឹមត្រូវនៅក្នុងអំឡុងនៃឆ្នាំ នោះអ្នកនឹងមិនទទួលបានប្រាក់បំពេញ ឬមានបំណុលទេ។

## របៀបគ្រប់គ្រងលើការបង់ប្រាក់របស់អ្នក

ជាការសំខាន់ត្រូវពិនិត្យមើលឡើងវិញនូវការប៉ាន់ស្មានប្រាក់ចំណូលគ្រួសាររបស់អ្នកឱ្យបានជាប្រចាំ។ ប្រសិនបើអ្នកបានប៉ាន់ស្មានប្រាក់ចំណូលគ្រួសាររបស់អ្នកតិចក្នុងពេលកន្លងមក ត្រូវធ្វើឱ្យប្រាកដថាការប៉ាន់ស្មានបច្ចុប្បន្នរបស់អ្នកគឺត្រឹមត្រូវ។ ធ្វើបច្ចុប្បន្នភាពវានៅពេលណាក៏ដោយដែលមានអ្វីផ្លាស់ប្តូរ។ ការធ្វើដូចនេះនឹងជួយអ្នកជៀសវាងនូវការបង់ប្រាក់លើស។

អ្នកគួរតែធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតការចូលរួមដែលបានទទួលស្គាល់របស់អ្នកសម្រាប់ Child Care Subsidy នៅរាល់ពេលដែលមានការផ្លាស់ប្តូរ។
យើងប្រើប្រាស់ការចូលរួមដែលបានទទួលស្គាល់កាលៈទេសៈគ្រួសាររបស់អ្នក អាយុកូនរបស់អ្នក ប្រភេទថែទាំដែលអ្នកប្រើប្រាស់ និងការប៉ាន់ស្មានប្រាក់ចំណូលគ្រួសាររបស់អ្នកដើម្បីគណនាចំនួន Child Care Subsidy ប៉ុន្មានដែលអ្នកអាចទទួលបាន។ ការបន្តរក្សាព័ត៌មានលម្អិតទាំងអស់របស់អ្នកឱ្យមានបច្ចុប្បន្នភាពនឹងជួយអ្នកជៀសវាងនូវការបង់ប្រាក់លើស។

វាក៏សំខាន់ផងដែរដែលអ្នកត្រូវបញ្ជាក់អំពីប្រាក់ចំណូលរបស់អ្នកនៅក្នុងរយៈពេល 1 ឆ្នាំ នៃចុងឆ្នាំហិរញ្ញវត្ថុដែលពាក់ព័ន្ធ។ ប្រសិនបើអ្នកមិនបញ្ជាក់អំពីប្រាក់ចំណូលរបស់អ្នកទេ នោះការបង់ប្រាក់របស់អ្នកអាចឈប់ ហើយអ្នកអាចត្រូវបង់សងវិញចំនួនពេញនៃ Family Tax Benefit ឬ Child Care Subsidy ដែលអ្នកបានទទួល។

## សម្រាប់ព័ត៌មានបន្ថែម

- ទៅកាន់ **servicesaustralia.gov.au/balancing** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- ទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលព័ត៌មានជាភាសារបស់អ្នកបាន
- សូមហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីការបង់ប្រាក់ និងសេវាកម្ម Centrelink
- សូមហៅទូរសព្ទទៅលេខ **132 011** សម្រាប់ Medicare និងលេខ **131 272** សម្រាប់ Child Support ។ សូមប្រាប់ឱ្យយើងដឹងប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ
- ចូលទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅ ‘13’ លេខពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលីគឺត្រូវបានគិតថ្លៃតាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទតាមតំបន់ ហើយក៏អាចប្រែប្រួលផងដែរក្នុងចំណោមអ្នកផ្តល់សេវាទូរសព្ទនានា។ ហៅទូរសព្ទទៅលេខ ‘1800’ ពីទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងពីទូរសព្ទចល័តអាចត្រូវបានកំណត់ម៉ោង ព្រមទាំងត្រូវបានគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# Balancing your family assistance payments

After the end of the financial year we compare your family income estimate with your actual income. This is to make sure we paid you the correct amount of family assistance. This process is called balancing.

## What you need to do

Not everyone has to do the same thing for us to balance their Family Tax Benefit and Child Care Subsidy. What you need to do depends on your circumstances.

You may need to lodge a tax return. If you have a partner, they may need to do this too. To check if you need to lodge a tax return go to the Australian Taxation Office (ATO) website.

If you or your partner lodge a tax return, the ATO will send us your income information. We usually get this information within 28 days from when you get your Notice of Assessment from them.

If you or your partner do not need to lodge a tax return, you need to let us know and confirm your family income. You can give us this information using either your Centrelink online account through myGov or Express Plus Centrelink mobile app.

If you separated from a partner during the financial year, we'll balance your Family Tax Benefit after you confirm your income. We'll use the income estimate provided for your ex-partner if they haven't lodged a tax return. If you got Child Care Subsidy, you will need to contact us to confirm your ex-partner's income. You don't need to contact your ex-partner for this information.

Most parents who pay or receive child support must lodge a tax return. When the ATO assesses your tax return, they will send us your income details. We will use this to update your child support assessment. If the ATO has not yet assessed your taxable income or if you do not need to lodge a tax return, you will still need to tell us your income. You can do this using your Child Support online account through myGov.

## When we balance your payments

We can only balance your Family Tax Benefit after we have paid your last Family Tax Benefit payment for the financial year and you have confirmed your income. You will usually get your last payment by the middle of July.

When we balance your Family Tax Benefit, we check if you should be paid any supplements. This includes Family Tax Benefit Part A supplement, Family Tax Benefit Part B supplement and Single Income Family Supplement.

We start balancing Child Care Subsidy later than Family Tax Benefit. Before we can balance your Child Care Subsidy, we confirm your child's attendance for the financial year. We get this directly from your child care service.

We withhold a percentage of your Child Care Subsidy to help offset any potential overpayments. If you do not have an overpayment, we will pay any amount we withheld directly to you when we balance your Child Care Subsidy.

Once we have balanced your payments, we will send you a letter to explain the outcome. If you get your letters electronically, we will send it to your myGov inbox. You can check if your Family Tax Benefit and Child Care Subsidy have been balanced using your Express Plus Centrelink mobile app. You can also check if your Child Care Subsidy has been balanced using your Centrelink online account through myGov.

# How to understand your balancing outcome

There are 3 possible balancing outcomes:

- you were not paid enough
- you were paid too much
- no change.

## You were not paid enough

If we did not pay you enough during the year, we will pay any outstanding amounts directly to you when we balance your payments. We call this a top up.

If you have a Centrelink debt, we may recover it from your Family Tax Benefit top up and supplements.

If you have a child care debt, we may recover it from your Child Care Subsidy and Additional Child Care Subsidy top ups.

This may happen even if you have entered into a repayment arrangement with us.

Family Tax Benefit top up payments and supplements may also be used by the ATO to recover tax debts.

## You were paid too much

If you got too much Child Care Subsidy or Family Tax Benefit during the year, you may owe us money, which you will have to pay back.

To pay the money back, you need to enter into a repayment plan with us. You must do this by the due date in your letter.

We may recover overpayments of Child Care Subsidy and Family Tax Benefit from all of the following:

- your future Family Tax Benefit payments,
- your Family Tax Benefit top up and supplements
- tax refunds.

We may recover child care overpayments from your Child Care Subsidy or Additional Child Care Subsidy top up

This may happen even if you have entered into a repayment arrangement with us.

You can check your Centrelink debts online. Select ‘**Money You Owe’** from your Centrelink online account through myGov or by using the Express Plus Centrelink mobile app.

If you disagree with a decision we have made, you can ask us to review it.

It is important you talk to us if you are worried about paying back a debt. We can work with you to set up a repayment plan you can afford.

## No change

If we have paid you the right amount during the year, you will not get a top up or debt.

## How to manage your payments

It is important to review your family income estimate regularly. If you have underestimated your family income in the past, make sure your current estimate is accurate. Update it whenever things change. This will help you avoid an overpayment.

You should update your recognised participation details for Child Care Subsidy every time there is a change. We use your family's circumstances, recognised participation, the age of your children, type of care you use and your family income estimate to work out how much Child Care Subsidy you can get. Keeping all your details up to date will help you avoid an overpayment.

It is also important you confirm your income within 1 year of the end of the relevant financial year. If you do not confirm your income, your payments may stop and you may have to repay the full amount of Family Tax Benefit or Child Care Subsidy you got.

# For more information

- Go to **servicesaustralia.gov.au/balancing** for more information in English
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language
- Call **131 202** to speak with us in your language about Centrelink payments and services
- Call **132 011** for Medicare and **131 272** for Child Support. Let us know if you need an interpreter, and we will arrange one for free
- Visit a service centre.

Note: calls from your home phone to '13' numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to '1800' numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

### Disclaimer

The information contained in this publication is intended only as a guide to payments and services. It is your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.